| | ២០០៤ | ២០០៥ | ២០០៦ |
|---|---|---|---|
| **ទិសដៅជាយុទ្ធសាស្ត្រទី ១ ការពារសិទ្ធិសេរីភាពរបស់បុគ្គល** | | | |
| ១.១.៤ ការបញ្ចូលសិទ្ធិមនុស្ស/ពលរដ្ឋវិទ្យាទៅក្នុងកម្មវិធីសិក្សាសាលារៀន | →→→→→→→→→→ →→→ X | | |
| ១.២.២ ការស្ទង់មតិលើកម្មវិធីបណ្តុះបណ្តាលបច្ចុប្បន្នពីសិទ្ធិមូលដ្ឋានសម្រាប់ទីភ្នាក់ងារអនុវត្តច្បាប់ ដើម្បីរកឱ្យឃើញចន្លោះប្រហោង និងកន្លែងដែលត្រូវកែលំអ | →→→→→→→→→→ →→→ X | | |
| ១.២.៣ បង្កើតកម្មវិធី និងសម្ភារៈបណ្តុះបណ្តាល រួមទាំងការបង្កើតមុខវិជ្ជាសិទ្ធិមនុស្សនៅកម្រិតសាកលវិទ្យាល័យ សម្រាប់កម្មវិធីបណ្តុះបណ្តាល វិជ្ជាជីវៈ និងបណ្តុះបណ្តាលបន្ត ( ការបណ្តុះបណ្តាលដំណោះស្រាយបញ្ហា និងឯកទេសចាំបាច់) | →→→→→→→→→→ →→→ X | | |
| ១.៤.៥ ពិនិត្យលទ្ធភាពធ្វើឱ្យប្រសើរឡើងនូវការរួមចំណែករបស់សង្គមស៊ីវិលក្នុងវិស័យច្បាប់ និងតុលាការ | →→→→→→→→→→ →→→ X | | |
| ១.៤.៦ ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ | →→→→→→→→→→ →→→ X | | |

## ទិសដៅជាយុទ្ធសាស្ត្រទី ១

**អាទិភាពកំណត់:**

១.១.៤ ការបញ្ចូលសិទ្ធិមនុស្ស និងពលរដ្ឋវិទ្យាទៅក្នុងកម្មវិធីសាលារៀន

១.២.២ ការស្ទង់មតិអំពីកម្មវិធីបណ្តុះបណ្តាលបច្ចុប្បន្នពីសិទ្ធិមូលដ្ឋានសម្រាប់ទីភ្នាក់ងារអនុវត្តច្បាប់ ដើម្បីរកឱ្យឃើញចន្លោះប្រហោង និងកន្លែងដែលត្រូវកែលំអ

១.២.៣ បង្កើតកម្មវិធី និងសម្ភារៈបណ្តុះបណ្តាល រួមទាំងការបង្កើតមុខវិជ្ជាសិទ្ធិមនុស្សនៅកម្រិតសាកលវិទ្យាលយ័ សម្រាប់កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងបណ្តុះបណ្តាលបន្ត ( ការបណ្តុះបណ្តាលដំណោះស្រាយបញ្ហា និងឯកទេស ចាំបាច់)

១.៤.៥ ពិនិត្យលទ្ធភាពធ្វើឱ្យប្រសើរឡើងនូវការរួមចំណែករបស់សង្គមស៊ីវិលក្នុងវិស័យច្បាប់ និងតុលាការ

១.៤.៦ ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ

| | |
|---|---|
| **ទិសដៅជាយុទ្ធសាស្ត្រ:** ពង្រឹងការការពារសិទ្ធិ និងសេរីភាពរបស់បុគ្គល | **លទ្ធផលរំពឹងទុក :** សិទ្ធិ និងសេរីភាពបុគ្គលត្រូវបានជំរុញ និងបង្កលក្ខណៈ |

| សកម្មភាពជាអាទិភាព | ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ | ស្ថាប័នដទៃទៀតដែលកំពុងមានការពាក់ព័ន្ធ | រយៈពេល | សកម្មភាពដែលត្រូវធ្វើ | សេចក្តីសង្កេតបន្ថែម |
|---|---|---|---|---|---|
| ១.១ ផ្តល់ការបណ្តុះបណ្តាលហ្វឹកហ្វឺន និងកម្មវិធីយល់ដឹងអំពីសិទ្ធិមនុស្ស និងសិទ្ធិជាមូលដ្ឋាន រួមទាំងសិទ្ធិពលរដ្ឋជាមូលដ្ឋានជាបឋមនៅកម្រិតសហគមន៍ គ្រឹះស្ថាន សហគ្រាសដោយយកចិត្តទុកដាក់ ជាពិសេសទៅលើស្ត្រី កុមារ និងអ្នកបាត់បង់ឱកាស រួមទាំងការបង្កើន និងការយល់ដឹងអំពីការចុះបញ្ជីសិទ្ធិ និងយន្តការបណ្តឹង | | | | | |
| ១.១.៤ ការបញ្ចូលសិទ្ធិមនុស្ស/ពលរដ្ឋវិទ្យាទៅក្នុងកម្មវិធីសាលារៀន | ក្រ.អប់រំ<br>គ.ក.ច.ន.យ<br>ក្រ.យុត្តិធម៌ | OSJI | ២០០៤-២០០៥ | ១-កំណត់កម្មវិធីសមស្របមួយ ដែលបញ្ចូលបញ្ញត្តិទូទៅអំពីសិទ្ធិមនុស្ស និងច្បាប់ទៅក្នុងកម្មវិធីសិក្សាមធ្យមភូមិ<br>២-រៀបចំសម្ភារៈឧបទ្ទេសសម្រាប់គ្រូ និងសៀវភៅសិក្សាសម្រាប់សិស្ស<br>៣-បណ្តុះបណ្តាលគ្រូនូវខ្លឹមសារនៃកម្មវិធីសិក្សាថ្មីនេះ | ក្នុងក្របខ័ណ្ឌនៃការប្រជុំបន្តពីសិក្ខាសាលាថ្នាក់ជាតិ ស្តីពីកំណែទម្រង់ អ.គ.គ បានដឹកនាំកិច្ចប្រជុំដំបូង ជាមួយក្រ.អប់រំ និងស្ថាប័នអន្តរជាតិដែលយកចិត្តទុកដាក់គាំទ្រគំនិតនេះ |
| ១.២ ផ្តល់ការបណ្តុះបណ្តាលហ្វឹកហ្វឺន និងការយល់ដឹងដល់មន្ត្រីទាំងឡាយ នៅក្នុងទីភ្នាក់ងារអនុវត្តច្បាប់អំពីសិទ្ធិមូលដ្ឋាន រួមទាំងសិទ្ធិពលរដ្ឋជាមូលដ្ឋាន និងសិទ្ធិមនុស្សដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងសមត្ថភាពអនុវត្តស្តង់ដាអន្តរជាតិ នៅពេលគ្មានច្បាប់ជាតិ ឬក្នុងករណីវិធាន/ច្បាប់ មានខ្លឹមសារប្រឆាំងគ្នាទៅវិញទៅមក | | | | | |
| ១.២.២ ការស្ទង់មតិអំពីកម្មវិធីបណ្តុះបណ្តាលបច្ចុប្បន្នពីសិទ្ធិមូលដ្ឋានសម្រាប់ទីភ្នាក់ងារអនុវត្តច្បាប់ ដើម្បីរកឱ្យឃើញចន្លោះប្រហោង និងកន្លែងដែលត្រូវកែលំអ | គ.ក.ច.ន.យ<br>ក្រ.យុត្តិធម៌<br>ក្រ.មហាផ្ទៃ | Aus-Aid<br>Licadho<br>Adhoc<br>គណៈកម្មការអន្តរជាតិសិទ្ធិមនុស្ស<br>កាកបាទក្រហមកម្ពុជា | ២០០៤-២០០៥ | ១-បង្កើតក្រុមការងារបច្ចេកទេសកំណត់វិស័យធ្វើការស្ទង់មតិ<br>២- ធ្វើការស្ទង់មតិ<br>៣- អនុវត្តអនុសាសន៍ទទួលបានពីការស្ទង់មតិ | ការបណ្តុះបណ្តាលជាច្រើនត្រូវបានអនុវត្តទៅលើនគរបាល និងទាហានរួចហើយ ។ ការស្ទង់មតិធ្វើឡើងដើម្បីចៀសវាងការ ខាតបង់កម្លាំង និងការជាន់ការងារគ្មានប្រយោជន៍ ។ អង្គការ CDPស្នើសុំចូលពាក់-ព័ន្ធក្នុងការស្ទង់មតិនេះដែរ ។ |

| | | | | | |
|---|---|---|---|---|---|
| ១.២.៣ បង្កើតកម្មវិធី និងសម្ភារៈបណ្តុះបណ្តាលរួមទាំងការបង្កើតមុខវិជ្ជាសិទ្ធិមនុស្សនៅកម្រិតសាកលវិទ្យាល័យ សម្រាប់កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងបណ្តុះបណ្តាលបន្ត (ការបណ្តុះបណ្តាលដំណោះស្រាយបញ្ហា និងឯកទេសចាំបាច់) | ក្រ.អប់រំ<br>ក្រ.មហាផ្ទៃ<br>ក្រ.យុត្តិធម៌<br>សា.ចៅក្រម<br>មជ្ឈមណ្ឌល. មេធាវី | | ២០០៤-២០០៥ | ១-ផ្តួចផ្តើមកិច្ចពិភាក្សាជាបឋមរវាងស្ថាប័នពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធទាំងអស់ ហើយក្សៀងគរដៃគូដែលយកចិត្តទុកដាក់គាំទ្រគំនិតនេះ<br>២-អភិវឌ្ឍន៍កម្មវិធីសិក្សា និងសម្ភារៈបណ្តុះបណ្តាល និងអនុវត្តកម្មវិធីបណ្តុះបណ្តាលដែលកំពុងដំណើរការ | មុខវិជ្ជាសិទ្ធិមនុស្សបានបញ្ចូលរួចខ្លះហើយទៅក្នុងកម្មវិធីសិក្សានៃសាកលវិទ្យាល័យមួយចំនួន |
| ១.៤ អនុម័ត និងពិនិត្យឡើងវិញនូវច្បាប់ការពារសិទ្ធិរបស់បុគ្គលក្នុងការរៀបចំអង្គការ បង្កើតសមាគម សម្តែងមតិ និងសិទ្ធិទទួលបានព័ត៌មាន ធានាឱ្យប្រព័ន្ធផ្សព្វផ្សាយ ស្ថាប័នស្រាវជ្រាវ និងសង្គមស៊ីវិល អាចអនុវត្តការត្រួតពិនិត្យមើល ប្រកបដោយប្រសិទ្ធភាពលើរចនាសម្ព័ន្ធរបស់រដ្ឋ អាចធ្វើរបាយការណ៍អំពីបញ្ហានោះ រួមទាំងផ្តល់ជាគំនិតដល់ដំណើរការនយោបាយ និងផ្តល់ចំណេះដឹងដោយមន្ត្រីអនុវត្តច្បាប់ ដើម្បីការពារសិទ្ធិទាំងនេះ | | | | | |
| ១.៤.៥ ពិនិត្យលទ្ធភាពធ្វើឱ្យប្រសើរឡើងនូវការរួមចំណែករបស់សង្គមស៊ីវិលក្នុងវិស័យច្បាប់ និងតុលាការ | ទី.គ.មន្ត្រី<br>ក.ក.ច.ន.យ<br>គ្រប់ក្រសួងស្ថាប័ន | | ២០០៤-២០០៥ | បន្តធ្វើការសម្របសម្រួលជាមួយសង្គមស៊ីវិលលើគ្រប់ទិដ្ឋភាពទាំងអស់នៃវិស័យ ហើយជាពិសេសក្នុងទំនាក់ទំនងជាមួយដំណើរការកំណែទម្រង់ច្បាប់ និងតុលាការ និងបង្កើតមធ្យោបាយទំនាក់ទំនង តួយ៉ាងព្រឹត្តិបត្រប្រចាំត្រីមាសអំពីភាពជឿនលឿននៃដំណើរការកំណែទម្រង់ជាដើម | |
| ១.៤.៦ ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ | ក្រ.កិច្ចការនារី<br>ក.ក.ច.ន.យ<br>ក្រ.យុត្តិធម៌<br>រដ្ឋសភា<br>ព្រឹទ្ធសភា | GTZ | ២០០៤-២០០៥ | ១- ត្រួតពិនិត្យឡើងវិញនូវសេចក្តីព្រាងច្បាប់បច្ចុប្បន្ន ដើម្បីធានាការស៊ីសង្វាក់គ្នាជាមួយស្តង់ដារអន្តរជាតិ និងគោលដៅសហវត្សដែលកំណត់ដោយរាជរដ្ឋាភិបាល<br>២- អនុម័តច្បាប់នេះហើយ បញ្ជូនទៅរដ្ឋសភាវិញ | |